# ដំណាក់កាលដើម្បីចូលសញ្ជាតិ



## ការផ្ញើសំបុត្រ

- Project Citizenship ផ្ញើពាក្យស្នើសុំដែលបំពេញរួចទៅកាន់ USCIS

## 1 ខែក្រោយការផ្ញើសំបុត្រ

- ទទួលបានការជូនដំណឹងអំពីការចូលប្រើគណនី *(មិនតម្រូវឱ្យមានសកម្មភាពអ្វីទេ)*
- ទទួលបានលិខិតជូនដំណឹង ឬលិខិតយល់ព្រមការលើកលែងថ្លៃសេវា *(ប្រសិនបើមាន)*

## 2 ខែក្រោយការផ្ញើសំបុត្រ

- ទទួលលិខិតណាត់ជួបដើម្បីផ្តិតម្រាមដៃ
- ចូលរួមការណាត់ជួបដើម្បីផ្តិតម្រាមដៃ
- ទុកស្នាមម្រាមដៃ និងថតរូប

## *5-9 ខែក្រោយការផ្ញើសំបុត្រ

- ទទួលលិខិតណាត់ជួបសម្ភាសន៍
- ចូលរួមការណាត់ជួបសម្ភាសន៍
- ធ្វើតេស្តផ្នែកភាសាអង់គ្លេស និងពលរដ្ឋវិជ្ជា**
- ឆ្លើយសំណួរអំពីការដាក់ពាក្យស្នើសុំ និងប្រវត្តិរូប

## *9-12 ខែក្រោយការផ្ញើសំបុត្រ

- ទទួលបានសេចក្តីជូនដំណឹងអំពីពិធីសម្បថ
- ចូលរួមក្នុងពិធីសម្បថ
- សងកាតបៃតងទៅ USCIS វិញ
- ទទួលបានវិញ្ញាបនប័ត្រនៃការចូលសញ្ជាតិ

## សូមអបអរសាទរ!

អ្នកមានសញ្ជាតិអាមេរិកហើយ

ប្រសិនបើអ្នកមានសំណួរសូមទាក់ទងមកយើងខ្ញុំតាមរយៈលេខ (617) 694-5949

** នេះគឺជារយៈពេលដែលគេបានគិតទុក*
*ចំពោះរយៈពេលពិតប្រាកដនៃការរៀបចំឯក*
*** ប្រសិនបើអ្នកធ្លាក់តេស្តភាសាអង់គ្លេស ឬ ពលរ*
*សម្ភាសន៍ឡើងវិញក្នុងរយៈពេល 2 ទៅ 3 ខែបន្ទាប់*

# តើស្ថានភាពផ្នែកអន្តោប្រវេសន៍របស់ខ្ញុំគឺជាអ្វី?

នៅពេលអ្នកបានទទួល **<u>បង្កាន់ដៃ</u>** ឬ**<u>ការលើកលែងថ្លៃសេវា</u>** នៅក្នុងប្រអប់សំបុត្រ លោកអ្នកអាចចាប់ផ្តើមពិនិត្យមើលស្ថានភាពផ្នែកអន្តោប្រវេសន៍របស់អ្នកបានតាមរយៈអ៊ីនធឺណិត ឬតាមទូរស័ព្ទ។ ជាទូទៅ នេះគឺជាសំបុត្រទីពីរដែលអ្នកនឹងទទួលពី USCIS (សំបុត្រលើកទីមួយគឺជាសេចក្តីជូនដំណឹង អំពីការចូលគណនី តែគ្មានព័ត៌មានអំពីស្ថានភាពករណី និងមិនតម្រូវការឱ្យមានសកម្មភាពណាមួយទេ)។ ជាធម្មតាអ្នកនឹងទទួលបានបង្កាន់ដៃ ឬការលើកលែងថ្លៃសេវា 4 ទៅ 6 សប្តាហ៍ក្រោយពីការដាក់បញ្ជូនពាក្យស្នើសុំរបស់អ្នក។ សូមរក្សាទុកការជូនដំណឹងនេះដើម្បីបន្តការពិនិត្យស្ថានភាពករណីរបស់អ្នក។ *សូមចងចាំថាវាជារឿងធម្មតាទេដែលអ្នកត្រូវរង់ចាំ ៣ទៅ៤ខែចន្លោះរវាងការណាត់ជួបនីមួយៗ។*

## *សេចក្តីណែនាំសម្រាប់ការពិនិត្យស្ថានភាពករណីរបស់តាមរយៈអ៊ីនធឺណិត៖*

1. ពិនិត្យមើលបង្កាន់ដៃ ឬការលើកលែងថ្លៃសេវារបស់អ្នក (សូមមើលឧទាហរណ៍នៅខាងក្រោម) ហើយស្វែងរក **<u>លេខបង្កាន់ដៃ</u>** ឬ **<u>លេខពាក្យស្នើសុំ</u>** ដែលស្ថិតនៅ ខាងលើផ្នែកខាងឆ្វេង។ ជាទូទៅ វាចាប់ផ្តើមដោយ <u>"NBC"</u> ឬ <u>"IOE" ។</u>


Department of Homeland Security
U.S. Citizenship and Immigration Services

Form I-797C, Notice of Action

THIS NOTICE DOES NOT GRANT ANY IMMIGRATION STATUS OR BENEFIT.

| | | | |
|---|---|---|---|
| Receipt | | | NOTICE DATE |
| CASE TYPE<br>N-400, Application for Naturalization | | | USCIS A# |
| RECEIPT NUMBER<br>IOE09046 | RECEIVED DATE | PRIORITY DATE | PAGE<br>1 of 1 |

APPLICANT NAME AND MAILING ADDRESS

PAYMENT INFORMATION:


Department of Homeland Security
U.S. Citizenship and Immigration Services

Form I-797C, Notice of Action

THIS NOTICE DOES NOT GRANT ANY IMMIGRATION STATUS OR BENEFIT.

| | | | |
|---|---|---|---|
| Fee Waiver Approved | | | NOTICE DATE |
| CASE TYPE<br>N-400, Application for Naturalization | | | USCIS A#<br>A205676 |
| RECEIPT NUMBER<br>IOE090467 | RECEIVED DATE | PRIORITY DATE | PAGE<br>1 of 1 |

APPLICANT NAME AND MAILING ADDRESS

PAYMENT INFORMATION:

2. ចូលទៅកាន់ [www.uscis.gov](http://www.uscis.gov) ហើយចុច "ពិនិត្យមើលស្ថានភាពករណីរបស់អ្នក"។ សូមមើលឧទាហរណ៍ខាងក្រោម។




3. វានឹងនាំអ្នកទៅទំព័រថ្មី ដែលអ្នកអាចដាក់បញ្ចូលលេខពាក្យស្នើសុំ ឬលេខបង្កាន់ដៃរបស់អ្នកចូលក្នុងប្រអប់។




4. នៅពេលអ្នកចុច "ពិនិត្យស្ថានភាព" អ្នកនឹងត្រូវនាំទៅទំព័រដែលនឹងប្រាប់អ្នកអំពីស្ថានភាពផ្នែកអន្តោប្រវេសន៍របស់អ្នក។



**ចំណាំ៖** វាមិនផ្តល់កាលបរិច្ឆេទ និងពេលវេលាច្បាស់លាស់នៃការណាត់ជួបរបស់អ្នកឡើយ។ វាគ្រាន់តែប្រាប់អ្នកថាការណាត់ជួបរបស់អ្នកត្រូវបានកំណត់ពេល ហើយសំបុត្រជូនដំណឹងត្រូវបានផ្ញើទៅកាន់លោកអ្នក។ ព័ត៌មានកាលបរិច្ឆេទ និងពេលវេលាការណាត់ជួបទាំងអស់នឹងត្រូវបានផ្ញើតាមរយៈសេចក្តីប្រកាស។ សូមប្រាកដថា ពិនិត្យមើលប្រអប់សំបុត្ររបស់អ្នកឱ្យបានទៀងទាត់ ។ ស្ថានភាពករណីរបស់អ្នកនៅលើបណ្តាញអ៊ីនធឺណិតមិនមែនជានិច្ច
កាលត្រូវបានគេកែប្រែទាន់ពេលនោះទេហើយវាប្រហែលមិនតំណាងស្ថានភាពជាក់ស្តែងនៃករណីរបស់លោកអ្នកឡើយ ។

## *សេចក្តីណែនាំសម្រាប់ការពិនិត្យមើលស្ថានភាពករណីរបស់អ្នកតាមទូរស័ព្ទរយៈ៖*

1. ទូរស័ព្ទទៅលេខ 1-800-375-5283
2. ចុចលេខ 1 ដើម្បីបន្តជាភាសាអង់គ្លេស ចុចលេខ 2 សម្រាប់ភាសាអេស្ប៉ាញ
3. ចុចលេខ 1 សម្រាប់សេវាអន្តោប្រវេសន៍
4. ចុចលេខ 1 ដើម្បីពិនិត្យមើលស្ថានភាពពាក្យស្នើសុំ
5. ចុចលេខ 1 ប្រសិនបើអ្នកដឹងលេខបង្កាន់ដៃរបស់អ្នក
6. បញ្ចូលលេខកូដ 13 តួរបស់អ្នក (ជាទូទៅចាប់ផ្តើមជាដោយ NBC* ឬ IOE)
7. ចុចលេខ 1 ដើម្បីបញ្ជាក់លេខដែលអ្នកបានវាយបញ្ចូល
8. ស្តាប់អំពើស្ថានភាពករណីនាពេលបច្ចុប្បន្នរបស់លោកអ្នក។

# ដំណាក់កាលនៃការចូលសញ្ជាតិ៖ សំណួរដែលសួរញឹកញាប់

## ចុះប្រសិនបើ...

### ខ្ញុំមិនទទួលសំបុត្រ?

ដំបូងទូរស័ព្ទ Project Citizenship ស្វែងរកមូលហេតុអ្វីអ្នកគ្មានទទួលបានការជូនដំណឹង ។
សូមពិនិត្យមើលអាសយដ្ឋាន (address) នៅលើច្បាប់ចម្លងនៃពាក្យស្នើសុំ (N-400) របស់អ្នកថាវាត្រឹមត្រូវឬអត់មុនចុះហត្ថលេខា។ ប្រសិនបើអ្នករកឃើញកំហុសឆ្គងណាមួយ ចូរអ្នកកែព័ត៌មាននោះជាមួយនឹង USCIS រួចហើយជូនដំណឹងទៅ Project Citizenship។

អ្នកត្រូវតែបំពេញជំហានទាំងពីរនៅខាងក្រោម៖

**1.** ផ្ញើសំបុត្រក្នុងទម្រង់សំណុំបែបបទ AR-11 ឬ បំពេញការផ្លាស់ប្តូរអាសយដ្ឋាននៅលើអ៊ីនធឺណិត (មាននៅគេហទំព័រ www.uscis.gov/ar-11)។

**2.** កែអាសយដ្ឋានរបស់អ្នកនៅលើពាក្យស្នើសុំដែលមិនទាន់សម្រេចណាមួយដោយទូរស័ព្ទទៅលេខ 1-800-375-5283 ។ ត្រូវត្រៀមលេខបង្កាន់ដៃរបស់អ្នក (អាចចាប់ផ្តើមដោយ NBC* ឬ IOE) ឲ្យបានរួចរាល់ជាមុន។

4 Faneuil South Market Building
3rd Floor
Boston, MA 02109
info@projectcitizenship.org

ទូរស័ព្ទ៖ (617) 694-5949
ទូរសារ៖ (617) 859-9993

# ដំណាក់កាលនៃការចូលសញ្ជាតិ៖
# សំណួរដែលសួរញឹកញាប់

## ចុះប្រសិនបើ...

### ខ្ញុំផ្លាស់ប្តូរលំនៅដ្ឋាន?

សូមអនុញ្ញាតឱ្យ Project Citizenship ដឹង ប្រសិនបើអាសយដ្ឋានសំបុត្ររបស់អ្នកមានការផ្លាស់ប្តូរ។ ប្រសិនបើការផ្លាស់ប្តូរទីលំនៅអ្នកមុនពេលពិធសម្បថ អ្នកត្រូវធ្វើការផ្លាស់ប្តូរអាសយដ្ឋានរបស់អ្នកជាមួយនឹង USCIS ។ សូមមើលជំហានទាំងពីរខាងលើសម្រាប់ការណែនាំ។

### ការលើកលែងថ្លៃសេវារបស់ខ្ញុំត្រូវបានបដិសេធ?

អ្នកអាចនៅតែមានសិទ្ធិទទួលបានការលើកលែងថ្លៃសេវា។

ប្រសិនបើការលើកលែងថ្លៃសេវារបស់អ្នកត្រូវបានបដិសេធនោះពាក្យស្នើសុំរបស់អ្នកនឹងត្រូវបានផ្ញើត្រឡប់មកវិញនៅតាមសំបុត្រ។ អ្នកប្រហែលជាត្រូវភ្ជាប់លិខិតអត្ថប្រយោជន៍ថ្មីរួមជាមួយច្បាប់ចម្លងនៃឯកសារពន្ធរបស់អ្នក ឬឯកសារ។ ប្រសិនបើអ្នកទទួលបានការបដិសេធនៃការលើកលែងថ្លៃសេវា

សូមទូរស័ព្ទមក Project Citizenship ។

4 Faneuil South Market Building
3rd Floor
Boston, MA 02109
info@projectcitizenship.org

ទូរស័ព្ទ៖ (617) 694-5949
ទូរសារ៖ (617) 859-9993

# ដំណាក់កាលនៃការចូលសញ្ជាតិ៖ សំណួរដែលសួរញឹកញាប់

## ចុះប្រសិនបើ...

### ខ្ញុំត្រូវធ្វើដំណើរ?

សូររកអ្នកណាម្នាក់ឱ្យពិនិត្យមើលសំបុត្រពេលដែលអ្នកនៅឆ្ងាយ ដូច្នេះអ្នកអាចដឹងពេលមានការជូនដំណឹងណាមួយ ។ ប្រសិនបើអ្នកត្រូវធ្វើដំណើរចំពេលដែលការណាត់ជួបជាមួយ USCIS អ្នកត្រូវស្នើសុំការណាត់ជួបថ្មីកំណត់ពេល មុនការចាកចេញដោយអនុវត្តតាមការណែនាំនៅលើសេចក្តីជូនដំណឹង។

### ខ្ញុំត្រូវការកំណត់ពេលណាត់ជួបឡើងវិញ?

អ្នកត្រូវផ្ញើលិខិតជូនដំណឹង និងលិខិតថ្លែងពីហេតុផលសម្រាប់ការកំណត់ជួបថ្មី ។ អាសយដ្ឋានរបស់ USCIS និងលេខទូរស័ព្ទមានស្ថិតនៅលើលិខិតជូនដំណឹងរបស់អ្នក។

### ខ្ញុំអវត្តមាននៅការណាត់ជួបរបស់ខ្ញុំ?

សូមមើលការណែនាំខាងលើ។ អ្នកក៏អាចទូរស័ព្ទទៅ USCIS តាមរយៈលេខ 1-800- 375-5283 ដើម្បីពន្យល់ពីមូលហេតុដែលអ្នកខកខានការណាត់ជួប រួចហើយស្នើសុំការណាត់ជួបថ្មី។ អ្នកត្រូវតែមានលេខបង្កាន់ដៃ (ចាប់ផ្តើមដោយ NBC* ឬ IOE) ឲ្យបានរួចរាល់ជាមុន។

4 Faneuil South Market Building
3rd Floor
Boston, MA 02109
info@projectcitizenship.org

ទូរស័ព្ទ៖ (617) 694-5949
ទូរសារ៖ (617) 859-9993

# ដំណាក់កាលនៃការចូលសញ្ជាតិ៖

# សំណួរដែលសួរញឹកញាប់

## ចុះប្រសិនបើ...

សូមចំណាំថា ប្រសិនបើអ្នកមិនទាក់ទង USCIS ក្នុងអំឡុងពេល 30 ថ្ងៃបន្ទាប់ពីខកខានការណាត់ជួប ពាក្យស្នើសុំរបស់អ្នកនឹងត្រូវបានបញ្ចប់។

### ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍របស់ខ្ញុំផុតកំណត់?

ប្រសិនបើប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ (កាតពណ៌បៃតង) ផុតកំណត់ អ្នកនៅតែអាចដាក់ពាក្យស្នើសុំ ឬ ស្ថិតក្នុងដំណាក់កាលនៃការដាក់ពាក្យស្នើសុំចូលសញ្ជាតិ។ អ្នកមិនអាចធ្វើដំណើរជាមួយកាត ដែលផុតកំណត់បានឡើយ។ ប្រសិនបើអ្នកត្រូវការកាតមានសុពលភាពដើម្បីធ្វើដំណើរ ឬសម្រាប់ការងាររបស់អ្នកមុនពេលអ្នកចូលសញ្ជាតិ អ្នកត្រូវបន្តកាតពណ៌បៃតងរបស់អ្នក។

### មិត្តភក្តិ ឬសមាជិកគ្រួសារខ្ញុំចង់ដាក់ពាក្យស្នើសុំ?

Project Citizenship ស្វាគមន៍មិត្តភក្តិ និងក្រុមគ្រួសាររបស់លោកអ្នក។ សូមផ្តល់លេខទូរស័ព្ទរបស់យើង ហើយឱ្យពួកគាត់ទូរស័ព្ទមកពួកយើងផ្ទាល់ ដូច្នេះពួកយើងអាចកំណត់បានថាតើពួកគាត់អាចចូលសញ្ជាតិបានឬអត់ទេ ។

4 Faneuil South Market Building
3rd Floor
Boston, MA 02109
info@projectcitizenship.org

ទូរស័ព្ទ៖ (617) 694-5949
ទូរសារ៖ (617) 859-9993

# ការចូលសញ្ជាតិសម្រាប់កូនៗរបស់អ្នក

ប្រសិនបើអ្នកមានកូនអាយុក្រោម 18 ឆ្នាំ ពួកគេអាចនឹងក្លាយជាសញ្ជាតិ
អាមេរិកបានកាលណាលោកអ្នកទទួលសញ្ជាតិអាមេរិក។

ដើម្បីចូលសញ្ជាតិបានកូនៗរបស់អ្នកត្រូវ៖

- មានអាយុក្រោម 18 ឆ្នាំ
- ជាអ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់ (អ្នកកាន់កាតពណ៌បៃតង)
- បច្ចុប្បន្នរស់នៅជាមួយអ្នក

ប្រសិនបើចំណុចទាំងអស់ខាងលើនេះជាការពិតនោះ Project Citizenship អាចជួយអ្នកដាក់ពាក្យសុំលិខិតបញ្ជាក់សញ្ជាតិសម្រាប់កូនៗរបស់អ្នកបានដរាបណាអ្នកក្លាយជាសញ្ជាតិអាមេរិក។

អ្នកនឹងត្រូវការ៖

- កាតពណ៌បៃតងរបស់កូនអ្នក
- សំបុត្រកំណើតរបស់កូនអ្នក
- ភស្តុតាងនៃសញ្ជាតិអាមេរិករបស់អ្នក
- សំបុត្រកំណើតរបស់អ្នក
- ភស្តុតាងនៃការស្ថិតក្រោមអាណាព្យាបាល
- ទឹកប្រាក់ $1,170 (លុះត្រាតែមានសិទ្ធិទទួលយកការលើកលែងថ្លៃសេវា)

នៅពេលដែលអ្នកមានឯកសារដែលត្រូវការ ទាំងអស់ សូមទាក់ទងមកកាន់ Project Citizenship តាមរយៈលេខទូរស័ព្ទ (617) 694-5949 ដើម្បីរៀបចំការណាត់ជួប។

តើអ្នករីករាយនឹង
បទពិសោធន៍របស់អ្នក
នៅថ្ងៃនេះដែរឬទេ?

សូមប្រាប់មិត្តភក្តិអ្នក!

projectcitizenship.org

(617) 694-5949


តើអ្នករីករាយនឹង
បទពិសោធន៍របស់អ្នក
នៅថ្ងៃនេះដែរឬទេ?

សូមប្រាប់មិត្តភក្តិអ្នក!

projectcitizenship.org

(617) 694-5949

តើអ្នករីករាយនឹង
បទពិសោធន៍របស់អ្នក
នៅថ្ងៃនេះដែរឬទេ?

សូមប្រាប់មិត្តភក្តិអ្នក!

projectcitizenship.org

(617) 694-5949

តើអ្នករីករាយនឹង
បទពិសោធន៍របស់អ្នក
នៅថ្ងៃនេះដែរឬទេ?

សូមប្រាប់មិត្តភក្តិអ្នក!

projectcitizenship.org

(617) 694-5949

**Did you enjoy your experience today?**

# Tell a friend!

PROJECT CITIZENSHIP

**projectcitizenship.org**

**(617) 694-5949**

**Did you enjoy your experience today?**

# Tell a friend!

PROJECT CITIZENSHIP

**projectcitizenship.org**

**(617) 694-5949**

**Did you enjoy your experience today?**

# Tell a friend!

PROJECT CITIZENSHIP

**projectcitizenship.org**

**(617) 694-5949**

**Did you enjoy your experience today?**

# Tell a friend!

PROJECT CITIZENSHIP

**projectcitizenship.org**

**(617) 694-5949**